**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៣១
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០១
**សាលដីកា**
លេខ:២៥
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............... ជាចៅក្រម
៤-លោក ................ ជាចៅក្រមរបាយការណ៍
៥-លោក .................. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក .................

**តំណាងមហាអយ្យការ**
-ឯកឧត្តម ............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះតាមលិខិតលេខ៧២ អក.បជ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញា អមតុលាការ ខេត្តបន្ទាយមានជ័យ សុំឱ្យឯកឧត្តមប្រធានតុលាការកំពូល កែតម្រូវលេខរដ្ឋបាល របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ។

- រវាងដើមចោទឈ្មោះលោក ឈយយ (ជាចុងបណ្តឹងសាទុក្ខ) អាយុ៤៩ឆ្នាំ មុខរបរលក់ដូរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

- និងចុងចម្លើយលោក សក(ជាម្ចាស់បណ្តឹងសាទុក្ខ) អាយុ៤៣ឆ្នាំ មុខរបរលក់ដូរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយបែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីទំហំ១៨៥ម គុណ ២១០ម និង សុំឲ្យចុងចម្លើយរុះរើផ្ទះចេញពីលើដីនោះ ។

តាមលិខិតលេខ៧២ អក.បជ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញា អមតុលាការ ខេត្តបន្ទាយមានជ័យ សុំឱ្យឯកឧត្តមប្រធានតុលាការកំពូល កែតម្រូវលេខរដ្ឋបាល របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៣១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះ ឈយយ និងប្រពន្ធ ឈ្មោះសេង សុខឃី ជាដើមចោទបានប្តឹងទាមទារដីចំការទំហំ១៨៥ម គុណ ២១០ម ស្ថិតនៅភូមិ ប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងសុំឲ្យចុងចម្លើយរុះរើផ្ទះចេញ ពីដីនោះ ដោយសំអាងហេតុថា ដីខាងលើនេះខ្លួនបានទទួលពីរដ្ឋអំណាចមូលដ្ឋានដែលបានប្រគល់ឱ្យ តាំងពីឆ្នាំ១៩៩៦ ដោយមានពាក្យស្នើសុំកាន់កាប់ និងប្រើប្រាស់ដីធ្លីត្រឹមត្រូវ តែក្រោយមកនៅ ឆ្នាំ១៩៩៨ ស្រាប់តែឃើញឈ្មោះសកទៅរស់នៅលើដីរបស់ខ្លួនទៅវិញ ទើបខ្លួនមិនសុខចិត្ត ហើយប្តឹងសុំឲ្យតុលាការជួយដោះស្រាយរកយុត្តិធម៌ដល់ខ្លួនតាមច្បាប់ ។

តាមពាក្យបណ្តឹងតបរបស់ឈ្មោះសកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០០ បានប្តឹងតបលើបណ្តឹងរបស់ឈ្មោះឈយយ និងប្រពន្ធក្នុងរឿងទាមទារដីទំហំ១៨៥ម គុណ ២១០ម ព្រមទាំងប្តឹងសុំសិទ្ធគ្រប់គ្រងដីចំការទំហំ១៧០ម គុណ ១៥០ម និងដីចំការទំ៥០ម គុណ ២១០ម ដែលស្ថិតនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដោយសំអាងហេតុថា ដីនេះខ្លួនទិញពីឈ្មោះអ៊ុំ សុផាត ទំហំ១៧០មx១៥០ម និងទិញពីឈ្មោះអាន ថា មានទំហំ២១០មx៥០ម ព្រមទាំងបានឲ្យសុរិយោដីស្រុកចុះវាស់វែងបញ្ជាក់ព្រំប្រទល់ថែមទៀត ។ ហើយថាអ៊ុំ សុផាត និងអាន ថា បានកាន់កាប់ដីនេះពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ១៩៩៨ មានលិខិតកាន់កាប់ដីធ្លីត្រឹមត្រូវ និងបានផ្ទេរសិទ្ធិដីនេះឲ្យមកខ្លួនក្នុងឆ្នាំ១៩៩៨ តាមរយៈរដ្ឋអំណាចឃុំ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២០១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការ ខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបញ្ជឹងចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០០ របស់ដើមចោទឈ្មោះឈិន យុឃាង និងអ្នកស្រី សេង សុឃី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតបចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០០ របស់ចុងចម្លើយឈ្មោះសកទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលខុស និងគតិច្បាប់ ។

៣-ប្រគល់ដីទំហំជាក់ស្តែងតាមប្លង់ទីតាំង ដែលការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ បានវាស់វែងគូសប្លង់ ដោយមិនគិតពីផ្លូវដែលអង្គការ NPA បានធ្វើកាលពីឆ្នាំ១៩៩៨ តាមលិខិតលេខ៨៨៦ ជនសកអដ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០០របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុក ចាប់ពីថ្ងៃដែលសាលក្រមនេះមានអានុភាពអនុវត្ត ។

៤-បង្គាប់ឲ្យចុងចម្លើយឈ្មោះសភរុះរើពីផ្ទះសំណង់ ដំណាំ និងការ្យទាំងពួង ដែលខ្លួនបានសង់ដោយសោហ៊ុយផ្ទាល់ខ្លួន នាំយកចេញឲ្យអស់ពីដីទំនាស់ចាប់ពីថ្ងៃដែលសាលក្រម មានអានុភាពអនុវត្តតទៅ ដោយខ្លួនត្រូវបង់ខាតសោហ៊ុយ និងទារជម្ងឺចិត្តអ្វីមិនបានឡើយ ។

៥-បង្គាប់ឲ្យចុងចម្លើយឈ្មោះសភបង់ប្រាក់ប្រដាប់ក្ដីចំនួន៧.០០០រៀល ដែលដើមចោទបង់ទុករួចហើយនោះ ឲ្យទៅដើមចោទវិញ និងបង្គាប់ឲ្យចុងចម្លើយឈ្មោះសភបង់ពន្ធសមាមាត្រ១ភាគរយលើតម្លៃដីទំនាស់ប៉ាន់ស្មាន ១០០.០០០បាត ស្មើនឹង១០០០បាត ដើម្បីបង់ចូលថវិការដ្ឋ៨០០បាត និងដើម្បីបង់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ស្មើនឹង២០០បាត តាមមាត្រា២.៣.២៣ និងមាត្រា៧៤ នៃច្បាប់ភូមិបាល ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី ហើយបើកសិទ្ធិឲ្យប្ដឹង ឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៨២ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះ សភប្ដឹងមិនសុខចិត្ត នឹងសាលក្រមរដ្ឋប្បវេណីលេខ២០១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២២(ឈ) ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០១របស់ឈ្មោះសភទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២០១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ដោយគ្រាន់តែសម្រេចបន្ថែមឃ្លាថា (ឲ្យទៅដើមចោទឈ្មោះឈិន យុយាង និងប្រពន្ធឈ្មោះសេង សុឃី កាន់កាប់ជាកម្មសិទ្ធិតទៅ) ។ ក្នុងចំណុចទី៣ នៃសេចក្ដីសម្រេចរបស់សាលក្រម ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍១៣.០០០រៀល ដែលដើមបណ្ដឹងបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល រង្វាន់អ្នក៥.០០០៛ ចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣០០០៛។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដីបើកផ្លូវប្ដឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ២៧៤ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ របស់ឈ្មោះសភប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ១២២(ឈ) ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីកាវដ្ឋប្បវេណីលេខ៣០០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ របស់តុលាការ កំពូល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលបណ្ដឹងសាទុក្ខលេខ២៧៤ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ របស់លោក ស្រីភាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្ដែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាវដ្ឋប្បវេណីលេខ១២២ (ឈ) ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រៀល ដែលលោកឈយយ បានបង់ជួសរួចហើយគឺ

- ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្ដែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សុរប១៩.០០០៛ ហើយតម្រូវឲ្យចុងចម្លើយសងប្រាក់១៩.០០០៛ នេះទៅដើមចោទវិញ ។

បង្គាប់ឲ្យចុងចម្លើយបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្ត បន្ទាយមានជ័យ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ ។

តាមលិខិតលេខ៧២ អក.បជ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញាអម តុលាការខេត្តបន្ទាយមានជ័យ សុំឱ្យឯកឧត្ដមប្រធានតុលាការកំពូល កែតម្រូវលេខរដ្ឋបាល របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និង ភូមិបាលស្រុកអូជ្រៅ ។

បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ ក្រោយពីបានពិនិត្យសំណុំរឿង មកឃើញថា ជារឿងដែលសុំឱ្យកែតម្រូវលិខិតរដ្ឋបាលរបស់កិរិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុកអូរជ្រៅ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

ឈ្មោះ សកបានឆ្លើយនៅពេលសវនាការថា នៅពេលចុះវាស់វែងក៏បានចូលរួមដែរ ដីដែលមានទំនាស់នៅឆ្ងាយពីដីរបស់ខ្លួន ក្រោយមកខ្លួនបានចូលរួមទៀតដោយបានឆ្លើយបំភ្លឺពីបញ្ហា ដីច្បាស់លាស់ហើយ គេក៏អនុញ្ញាតឱ្យខ្លួនមកផ្ទះវិញ រួចបែរជាពួកគេចោទថា ខ្លួនបានគំរាមគំហែងគេទៅវិញ ខ្លួនមិនយល់ព្រមតាមការទាមទាររបស់ឈ្មោះឈយយ ទេ ព្រោះដីរបស់ខ្លួនស្ថិតនៅ ខាងកើតសាលា ឯដីដែលគាត់ទាមទារនៅខាងជើងសាលាទេ ខ្លួនមិនជំទាស់ទេ ចំណែកដីរបស់ខ្លួន មានប្លង់ច្បាស់លាស់ហើយ ។ តាមការពិតនោះជាការឃុបឃិតគ្នាជាមួយដើមចោទ និងរដ្ឋអំណាច លួចគូសប្លង់ដីរបស់ខ្លួនមកដាក់ក្នុងសំណុំរឿង រឿងវាពាក់ព័ន្ធជាមួយនឹងសេង សូគី ដែលគាត់ជាគណៈកម្មាធិការចូលរួមក្នុងការបែងចែកដីដោយអ្នកស្រីនោះបានធ្វើកោសលប់ចំហំដីមានលក្ខណៈ មិនប្រក្រតីឡើយ ។

សូមឯកឧត្តមមេត្តាសម្រេចសេចក្តីតាមយុត្តិធម៌ ។

ឈ្មោះឈិន យុយាង បានឆ្លើយនៅពេលសវនាការថា លិខិតកាន់កាប់ដីរបស់ខ្លួនមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ គឺពីផ្លូវប្រឡាយចំការដែលមានរហូតមកដល់សព្វថ្ងៃ មិនមែនពីខាងជើងចំទៅចំណែកការចុះវាស់វែងដីនេះ គឺបានចុះទៅពិនិត្យទាំងអស់គ្នា ដោយមានទាំងកំណត់ហេតុត្រឹមត្រូវ តាមច្បាប់ រឿងនេះបានសម្រេចសេចក្តីចប់ហើយ សាលដីការបស់តុលាការកំពូលក៏ខ្លួនបានយកទៅ អនុវត្តហើយ តែនេះគ្រាន់តែកែតម្រូវផ្នែករដ្ឋបាលប៉ុណ្ណោះ ដោយមានការច្រឡំលេខ ហើយដីនេះ មានព្រំប្រទល់ច្បាស់លាស់ណាស់មិនអាចមានការក្លែងបន្លំបានឡើយ ព្រោះនមានគណៈកម្មាធិការួម ទាំងភាគីទាំងសងខាងមិនអាចដូចពាក្យដែល ឈ្មោះសកបានលើកឡើងឡើយ ។

ដូច្នេះសូមឯកឧត្តមមេត្តាសម្រេចកែតម្រូវលេខ ឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសរបស់ការិយាល័យដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី ពឹង ធីតា ជាមេធាវីការពារឱ្យលោកសកនៅពេលសវនាការថា ៖ សាលដីការបស់តុលាការកំពូលបានក្លាយជាស្ថាពរទៅហើយ តែការអនុវត្តន៍មិនបានមកពីមានការភ័ន្តច្រឡំលេខ ។

ចំពោះសាលក្រមលេខ២០១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ជំរះ និងប្រកាសនៅថ្ងៃតែមួយដដែល ហើយក្នុងសាលក្រមបែរជាដាក់ថ្ងៃប្រកាសខុសគ្នាទៅវិញ

-កិច្ចសន្យាចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៦ ដែលមានសំអាងហេតុច្បាស់លាស់ត្រឹមត្រូវតែបើពិនិត្យទៅឃើញថា មានការកោសលប់ទៀត ហើយស្នាមមេដៃក៏មិនត្រឹមត្រូវទៀត

-តុលាការសម្រេចសេចក្តី ហើយបានគេចុះទៅវាស់ដីជាក្រោយវិញ ទាំងអស់នេះហើយសុទ្ធតែជាលក្ខណៈកើតឡើងមិនប្រក្រតី

បើពិនិត្យពីចំងាយដីទំនាស់ឃើញថា មានលក្ខណៈខុសគ្នាឆ្ងាយណាស់ ហើយការពង្រីកសាលាមានរហូតដល់ទៅពីរកន្លែងបណ្តាលឱ្យតុលាការមានការភ័ន្តច្រឡំពីព្រំប្រទល់ ។

ដូច្នេះដើម្បីបញ្ជាក់ពីការពិតឱ្យបានច្បាស់ខ្លួនសុំអនុញ្ញាតឱ្យតុលាការបង្កើតគណកម្មការចំរុះ ទៅពិនិត្យដល់ទីកន្លែងដីទំនាស់ឡើងវិញ ព្រោះទពេលអនុវត្តសាលដីកាបណ្តាលឱ្យមានការប៉ះពាល់ ដល់ដីអ្នកដទៃទៀត ។

សូមឯកឧត្តមមេត្តាអនុញ្ញាតតាមការសុំនេះដោយក្តីអនុគ្រោះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា លិខិតលេខ៧២ អក បជ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យ សុំឲ្យតុលាការកំពូល កែតម្រូវលេខបីខិតរដ្ឋបាលរបស់ ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ នៅក្នុងសាលក្រមលេខ២០១ ចុះថ្ងៃទី១២ ខែធ្នូឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យនោះ មានលក្ខណៈសមស្របតុលាការកំពូលអាចទទួលជំនុំជំរះបានតាមគោលការណ៍យុត្តិសាស្ត្រ ។

-យល់ឃើញថា សាលក្រមរដ្ឋប្បវេណីលេខ២០១ ចុះថ្ងៃទី១២ខែធ្នូ ឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ មានការភ័ន្តច្រឡំត្រង់ចំណុចទី៣ នៃសេចក្តីសម្រេចប្រគល់ដីទំនាស់ ដាក់ស្តែងតាមប្លង់ទីតាំងដែលការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុក អូរជ្រៅបានវាស់វែងតាមលិខិតលេខ៨៨៦ ជនសភអជ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០០ នោះការពិតគឺលិខិតលេខ២៨៦ ជនសភអជ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០០ ទេ ។

-យល់ឃើញថា ដោយការខុសឆ្គងនេះ ជាកំហុសផ្នែកសំភារៈដូច្នេះតុលាការកំពូលគប្បីកែ តម្រូវ ។

-យល់ឃើញថា ការដែលមេធាវីចុងចម្លើយសុំឱ្យបដិសេធសាលដីកាតុលាការកំពូលលេខ៣០០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០២ បង្កើតគណកម្មការចុះទៅពិនិត្យទីតាំងដីទំនាស់នោះ តុលាការកំពូលពុំមានសមត្ថកិច្ចធ្វើការសើរើបានឡើយ ។

### ហេតុដូច្នេះ
### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលលិខិតលេខ៧២ អក.បជ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- កែតម្រូវសាលក្រមរដ្ឋប្បវេណីលេខ២០១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០ របស់តុលាការ ខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទី៣ តាមលិខិតលេខ៨៨៦ ជនសភអជ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០០ មកជាលេខ២៨៦ ជនសភអជ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០០ វិញ ។

៣- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ។